01329130

E421/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 21 / 09 / 2016
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ចំពោះមុខ: ចៅក្រម យ៉ា សុខន ជ.ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូរ ឧត្តារ
ចៅក្រម Claudia FENZ
ចៅក្រម ធូ មណី

កាលបរិច្ឆេទ: ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៦

ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

---

# សេចក្ដីសម្រេចលើសំណើសុំស្ដីពី កាលបរិច្ឆេទកំណត់ តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង

---

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GIRAUD

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើសុំរបស់ភាគីស្តីពីកាលបរិច្ឆេទកំណត់សម្រាប់សំណើសុំតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សម្រាប់ភស្តុតាងថ្មីក្នុងសំណុំរឿង ០០២/០២។

២. នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា សំណើសុំទាំងអស់តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក្នុងសំណុំរឿង ០០២/០២ ត្រូវដាក់នៅមុន ឬ ត្រឹមថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦។ អង្គជំនុំជម្រះកត់សម្គាល់ថា ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះនឹងពិចារណាទៅលើសំណុំសុំដាក់ភស្តុតាងថ្មី ដែលដាក់ក្រោយកាលបរិច្ឆេទកំណត់នេះ ឬ សំណើសុំដាក់ភស្តុតាងដោះបន្ទុក[1]។

៣. នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៦ មេធាវីការពារក្តី នួន ជា បានស្នើសុំតាមសារអេឡិចត្រូនិកថា គួរមានកិច្ចប្រជុំរៀបចំសវនាការមួយ ដើម្បីពិភាក្សាស្តីពីការដាក់បង្ហាញឯកសារថ្មីៗ ដោយសហព្រះរាជអាជ្ញា និង អំពីកាលបរិច្ឆេទកំណត់ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ ដែលបានកំណត់សម្រាប់សំណើសុំតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះបានអនុញ្ញាតតាមសំណើសុំ និង បានស្តាប់សារណារបស់ភាគីនានាអំពីបញ្ហាទាំងអស់នេះនៅក្នុងកិច្ចប្រជុំរៀបចំសវនាការមួយ កាលពីថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦។ នៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចរបស់ខ្លួនលើសំណើសុំនានាពាក់ព័ន្ធនឹងពេលវេលាកំណត់ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ហើយនៅពេលនេះ អង្គជំនុំជម្រះផ្តល់សំអាងហេតុសម្រាប់សេចក្តីសម្រេចនេះ[2]។

## ២. សារណា

៤. មេធាវីការពារក្តី នួន ជា បានលើកឡើងថា ការិយាល័យសហព្រះរាជអាជ្ញានឹងដាក់បន្ទុកការលំបាកយ៉ាងច្រើនហួសហេតុចំពោះមេធាវីការពារក្តី ក្នុងករណីដែលសហព្រះរាជអាជ្ញាដាក់សំណើសុំបង្ហាញឯកសារ និង/ឬដាក់សំណើសុំឱ្យទទួលយកធ្វើជាឯកសារភស្តុតាង អនុលោមតាមវិធាន

---

[1] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "ដំណាក់កាលចុងក្រោយនៃសំណុំរឿង ០០២/០២– ការជូនដំណឹងអំពីកាលបរិច្ឆេទផ្សេងៗ", ឯកសារ E421, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៦ ("អនុស្សរណៈស្តីពីពេលវេលាកំណត់"), កថាខណ្ឌ ៣។

[2] សេចក្តីសម្រេចលើសំណើនានាពាក់ព័ន្ធនឹងកាលបរិច្ឆេទកំណត់អនុលោមតាម វិធាន៨៧(៤) នៃវិធានផ្ទៃក្នុង, ឯកសារ E421/3, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៦។

៨៧(៤) នៃវិធានផ្ទៃក្នុង កៀកទៅនឹងកាលបរិច្ឆេទកំណត់ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦[3] ពេក។ ហេតុដូច្នេះ មេធាវីការពារក្ដី នួន ជា ស្នើសុំឱ្យពន្យារកាលបរិច្ឆេទកំណត់ទៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៦ វិញ ដើម្បីឆ្លើយតបទៅនឹងសំណើសុំទាំងអស់របស់សហព្រះរាជអាជ្ញាដែលបានដាក់នៅមុន ឬ នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦[4]។ មេធាវីការពារក្ដី នួន ជា ក៏បានស្នើសុំកុំឱ្យអង្គជំនុំ-ជម្រះអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាស្នើសុំឱ្យទទួលយកសម្ភារៈដាក់បន្ទុកពីសំណុំរឿង ០០៣ និង ០០៤ នៅក្រោយថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១៦ ដោយសារតែភាគីនានាគួរតែមានលទ្ធភាពពឹងផ្អែកទៅលើកំណត់ត្រាភ័ស្តុតាងដែលមាននាពេលបច្ចុប្បន្ន។ មេធាវីការពារក្ដីក៏បានលើកឡើងបន្ថែមថា សម្ភារៈដែលត្រូវបានដាក់បង្ហាញមកដល់ពេលនេះ គឺជាសម្ភារៈដាក់បន្ទុក មិនមែនដោះបន្ទុកនោះឡើយ ហើយមេធាវីការពារក្ដីបានស្នើសុំអង្គជំនុំជម្រះឱ្យតម្រូវឱ្យសហព្រះរាជអាជ្ញាបង្ហាញពីចំណុចដោះបន្ទុកនៃសម្ភារៈដែលបានដាក់បង្ហាញ[5]។ ជាចុងក្រោយ មេធាវីការពារក្ដី នួន ជា លើកឡើងថា សម្ភារៈដោះបន្ទុកអាចទទួលយកបាននៅគ្រប់ដំណាក់កាល ដោយសារតែការធ្វើបែបនេះគឺជាប្រយោជន៍នៃយុត្តិធម៌ ដូច្នេះហើយ មេធាវីការពារក្ដីទទួលស្គាល់ថា ការដាក់បង្ហាញនេះគួរបន្តធ្វើរហូតដល់ពេលក្រោយថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ ដោយការអនុវត្តនេះសម្រាប់តែសម្ភារៈដោះបន្ទុកបែបនេះតែប៉ុណ្ណោះ[6]។

៥. មេធាវីការពារក្ដី ខៀវ សំផន បានស្នើសុំឱ្យពន្យារកាលបរិច្ឆេទសម្រាប់ឆ្លើយតបចំពោះសំណើសុំនានារបស់សហព្រះរាជអាជ្ញាដែលកើតចេញពីការដាក់បង្ហាញសម្ភារៈថ្មីៗ ទោះបីជាសំណើសុំនោះជាសំណើតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ឬ គ្រាន់តែជាការដាក់បង្ហាញសម្ភារៈដែលអាចមានលក្ខណៈដោះបន្ទុកក៏ដោយ[7]។ មេធាវីការពារក្ដី ខៀវ សំផន ក៏បានលើកឡើងផងដែរថា មេធាវីកាពារក្ដីគួរទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីស្នើសុំឱ្យទទួលយកឯកសារមួយចំនួន ឬ ឆ្លើយតបចំពោះការដាក់ឯកសារបែបនេះ[8]។ មេធាវីការពារក្ដីលើកឡើងបន្ថែមថា កាលបរិច្ឆេទកំណត់ក្នុងការឆ្លើយតបចំពោះការដាក់សារណាបែបនេះ គួររាប់តែចាប់ពីពេលដែលមេធាវីការពារក្ដីបាន

[3] ប្រតិចារឹកថ្ងៃទី ០៤ ខែសីហា ឆ្នាំ ២០១៦, ទំព័រ ៥-៦ (សេចក្ដីព្រាង)។

[4] ប្រតិចារឹកថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦, ទំព័រ ២៨-២៩, ៣៧-៣៨ (សេចក្ដីព្រាង)។

[5] ប្រតិចារឹកថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦, ទំព័រ ៨-៩ (សេចក្ដីព្រាង)។

[6] ប្រតិចារឹកថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦, ទំព័រ ១០, ២៦ ដល់២៧ (សេចក្ដីព្រាង)។

[7] ប្រតិចារឹកថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦, ទំព័រ ១៤ ដល់១៦ (សេចក្ដីព្រាង)។

[8] ប្រតិចារឹកថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦, ទំព័រ ១៧ ដល់២០ (សេចក្ដីព្រាង)។

01329133



ទទួលសិទ្ធិចូលពិនិត្យមើលសម្ភារៈដែលបានដាក់បង្ហាញប៉ុណ្ណោះ[9]។ មេធាវីកាពារក្តី ខៀវ សំផន បានលើកឡើងថា ពេលវេលាបួនសប្តាហ៍ចាប់ពីពេលដាក់បង្ហាញឯកសារនឹងអនុញ្ញាតឱ្យមេធាវីកាពារក្តីអាចឆ្លើយតបទៅនឹងសារណាដែលដាក់ដោយសហព្រះរាជអាជ្ញា[10]។ មេធាវីកាពារក្តី ខៀវ សំផន បានលើកឡើងថា មិនគួរមានកាលបរិច្ឆេទកំណត់សម្រាប់មេធាវីការពារក្តីក្នុងការស្នើសុំឱ្យទទួលយកសម្ភារៈដោះបន្ទុកនោះឡើយ[11]។ មេធាវីកាពារក្តី ខៀវ សំផន បានស្នើថា កាលបរិច្ឆេទកំណត់សម្រាប់មេធាវីកាពារក្តីទាំងអស់ ក្នុងការឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដែលបានដាក់នៅមុន ឬ នៅថ្ងៃទី ០១ ខែ កញ្ញា គួរត្រូវបានពន្យារពេលរហូតដល់ថ្ងៃទី ៣០ ខែ កញ្ញា ដើម្បីឱ្យមេធាវីការពារក្តីអាចរៀបចំការងាររបស់ខ្លួនបានត្រឹមត្រូវ[12]។

៦. មេធាវីកាពារក្តី ខៀវ សំផន ក៏បានដាក់សំណើសុំឱ្យអង្គជំនុំជម្រះផ្តល់ដល់ភាគីនានាឱ្យបានឆាប់រហ័សបំផុត នូវបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញចុងក្រោយ ដែលត្រូវកោះហៅសម្រាប់ប្រធានបទចុងក្រោយនៅក្នុងសំណុំរឿង ០០២/០២[13]។ មេធាវីកាពារក្តីបានកត់សម្គាល់ថាប្រសិនបើមិនមានបញ្ជីចុងក្រោយនេះទេ ខ្លួនមិនអាចកំណត់អត្តសញ្ញាណឯកសារថ្មីៗទាំងអស់ ដែលខ្លួនមានបំណងស្នើសុំឱ្យទទួលយកនៅក្នុងសំណុំរឿង ០០២/០២ ឡើយ[14]។

---

[9] ប្រតិចារឹកថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦, ទំព័រ ២០ (សេចក្តីព្រាង); *សូមមើលផងដែរ* សំណើរបស់មេធាវីការពារក្តីលោក ខៀវ សំផន សុំពន្យារពេលឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលស្នើសុំឱ្យទទួលយកធ្វើជាធ្វើភ័ស្តុតាងនូវឯកសារចំនួន ៣៥ ពីក្នុងសំណុំរឿង ០០៣ និង ០០៤ (E319/52), ឯកសារ E319/52/1, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ ("សំណើសុំពន្យាលពេល"), កថាខណ្ឌ ១០ ដល់ ១២។ កាលបរិច្ឆេទកំណត់សម្រាប់ចម្លើយតបចំពោះឯកសារ E319/52 ត្រូវបានដោះស្រាយផ្សេងដោយអង្គជំនុំជម្រះ។ សូមមើលសេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យាពេលឆ្លើយតបចំពោះសារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ E319/52, E319/52/2, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦ (ឯកសារថត-ចម្លងត្រូវបានផ្ញើជូនភាគី តាមសារអេឡិចត្រូនិក នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៦)។

[10] ប្រតិចារឹកថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០១៦, ទំព័រ ៣០ (សេចក្តីព្រាង)។

[11] ប្រតិចារឹកថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០១៦, ទំព័រ ៣៩, ៤២ (សេចក្តីព្រាង)។

[12] ប្រតិចារឹកថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០១៦, ទំព័រ ៤២ (សេចក្តីព្រាង)។

[13] សំណើរបស់មេធាវីការពារក្តីលោក ខៀវ សំផន សុំឱ្យផ្ញើបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញដែលនឹងត្រូវកោះហៅឱ្យមកផ្តល់សក្ខីកម្ម សម្រាប់ដំណាក់កាលចុងក្រោយនៃសំណុំរឿង ០០២/០២, ឯកសារ E421/2, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៦ ("សំណើសុំបញ្ជីសាក្សីស្ថាពរ"), កថាខណ្ឌ ៩។

[14] សំណើសុំបញ្ជីសាក្សីស្ថាពរ, កថាខណ្ឌ ៥។

៧. សហព្រះរាជអាជ្ញាអន្តរជាតិបានទទួលស្គាល់ពីកាតព្វកិច្ចជាបន្តរបស់សហព្រះរាជអាជ្ញាក្នុងការដាក់បង្ហាញសម្ភារៈដោះបន្ទុក និង លើកឡើងថា ចំណុចនេះត្រូវបានកំណត់ជាអាទិភាព[15]។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ចំនួនឯកសារដែលត្រូវបានដាក់បង្ហាញចំពោះមេធាវីការពារក្តីក្នុងពេលថ្មីៗនេះ គឺក្នុងអំឡុងខែ កក្កដា ឆ្នាំ ២០១៦ មិនច្រើនទេនៅក្នុងបរិបទនៃរឿងក្តីព្រហ្មទណ្ឌអន្តរជាតិ ហើយថា សហព្រះរាជអាជ្ញាមានកាតព្វកិច្ចក្នុងការត្រួតពិនិត្យមើលឯកសារក្នុងសំណុំរឿង ០០៣ និង ០០៤ សម្រាប់លទ្ធភាពក្នុងការដាក់បង្ហាញ[16]។ រដ្ឋអាជ្ញាក្នុងប្រព័ន្ធច្បាប់ស៊ីវិលមានកាតព្វកិច្ចដូចគ្នាក្នុងការស្នើសុំឱ្យទទួលយកព័ត៌មានដាក់បន្ទុក[17]។ ទោះបីជាមិនមានការរំពឹងទុកថា ឯកសារជាច្រើនបន្ថែមទៀតនឹងត្រូវដាក់បង្ហាញ ដោយផ្អែកលើមូលដ្ឋានដែលឯកសារទាំងនោះមានសម្ភារៈដោះបន្ទុកក៏ដោយ ក៏ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅលើចំណុចថាតើត្រូវអនុញ្ញាតដែរ ឬ យ៉ាងណាចំពោះការដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយចំនួន ៤៥ ពីក្នុងសំណុំរឿង ០០៣ និង សំណុំរឿង០០៤ កំពុងស្ថិតក្នុងការរង់ចាំនៅឡើយ ហើយអាចមានកំណត់ហេតុស្តាប់ចម្លើយបន្ថែមចំនួន ២០ ទៀត ដែលជាកម្មវត្ថុនៃសំណើសុំដាក់បង្ហាញនាពេលខាងមុខ[18]។ សហព្រះរាជអាជ្ញាអន្តរជាតិមានបំណងបញ្ចប់ដំណើរការដាក់បង្ហាញសម្ភារៈដែលមាននាពេលនេះ ត្រឹមថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦[19]។

៨. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សារណាឡើយ។

## ៣. សំអាងហេតុ

### ៣.១ ការដាក់បង្ហាញព័ត៌មានដោះបន្ទុក

៩. អង្គជំនុំជម្រះសូមរម្លឹកពីសេចក្តីសម្រេចរបស់ខ្លួន កាលពីថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ ដែលក្នុងសេចក្តីសម្រេចនោះ អង្គជំនុំជម្រះបានញែកពីគ្នារវាងកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការដាក់បង្ហាញព័ត៌មានដែលអាចមានលក្ខណៈដោះបន្ទុកអនុលោមតាមវិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង

[15] ប្រតិចារិកថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦, ទំព័រ១២ (សេចក្តីព្រាង)។

[16] ប្រតិចារិកថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦, ទំព័រ ៣ ដល់៤ (សេចក្តីព្រាង)។

[17] ប្រតិចារិកថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦, ១២, ៣៣, ៣៥ ដល់៣៦ (សេចក្តីព្រាង)។

[18] ប្រតិចារិកថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦, ទំព័រ ៥ ដល់៧ (សេចក្តីព្រាង)។

[19] ប្រតិចារិកថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦, ទំព័រ ៧, ៣០ (សេចក្តីព្រាង)។

និង សិទ្ធិក្នុងការស្នើសុំឱ្យទទួលយកភស្តុតាងថ្មី អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង[20]។ ជនជាប់ចោទមានសិទ្ធិជាមូលដ្ឋានក្នុងការចូលពិនិត្យសម្ភារៈដែលអាចមានលក្ខណៈដោះបន្ទុក[21]។ ហេតុដូច្នេះ កាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការដាក់បង្ហាញសម្ភារៈទាំងនេះ មិនមែនអាស្រ័យទៅលើពេលវេលាកំណត់ណាមួយឡើយ ហើយត្រូវបន្តរហូតដល់ពេលបញ្ចប់សំណុំរឿង ០០២/០២។ កាតព្វកិច្ចដាក់បង្ហាញសម្ភារៈដោះបន្ទុកពីសំណុំរឿង ០០៣ និង ០០៤ ត្រូវធ្លាក់ទៅសហព្រះរាជអាជ្ញា ព្រោះសហព្រះរាជអាជ្ញាមានសិទ្ធិចូលពិនិត្យមើលកិច្ចស៊ើបសួរដែលកំពុងដំណើរការនៅក្នុងសំណុំរឿងទាំងនោះ ចំណែកជនជាប់ចោទក្នុងសំណុំរឿង ០០២ មិនមានសិទ្ធិនោះទេ។ យ៉ាងណាក៏ដោយ អង្គជំនុំជម្រះសូមរម្លឹកដល់ភាគីថា ឯកសារដែលបានដាក់បង្ហាញមិនត្រូវបានទទួលយកជាស្វ័យប្រវត្តិ ឬ ដាក់ជាស្វ័យប្រវត្តិនៅចំពោះមុខអង្គជំនុំជម្រះឡើយ[22]។ ឯកសារដែលបានដាក់បង្ហាញ ត្រូវបានផ្តល់ជូនភាគី ដើម្បីឱ្យមេធាវីការពារក្តីមានឱកាសអាចប្រើប្រាស់ភស្តុតាងដែលអាចដោះបន្ទុក តាមរយៈការស្នើសុំឱ្យទទួលយកដោយធ្វើសំណើសុំ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

១០. មេធាវីការពារក្តីមិនបានបង្ហាញពីយុត្តិសាស្ត្រណាមួយដែលធ្វើឱ្យសហព្រះរាជអាជ្ញា បន្ថែមពីលើកាតព្វកិច្ចក្នុងការដាក់បង្ហាញ មានកាតព្វកិច្ចក្នុងការចង្អុលបង្ហាញផ្នែកណាខ្លះនៃឯកសារដែលបានដាក់បង្ហាញថាអាចដោះបន្ទុកនោះទេ។ មិនមានការលើកឡើងថា សហព្រះរាជអាជ្ញាបានអនុវត្តដោយចេតនាអាក្រក់ ហើយក៏មិនមានការបង្ហាញណាមួយថា ទំហំ ឬ លក្ខណៈនៃការដាក់បង្ហាញនោះ អាចបង្កព្យសនកម្មខ្លាំងទៅលើជនជាប់ចោទឡើយ[23]។ ការដាក់បង្ហាញទាំងអស់នេះត្រូវបាន

---

[20] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា, ឯកសារ E363/3, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ ("សេចក្តីសម្រេចលើការដាក់បង្ហាញឯកសារ"), កថាខណ្ឌ ២០ ដល់ ៣០។

[21] សេចក្តីសម្រេចលើការដាក់បង្ហាញឯកសារ, កថាខណ្ឌ ២២។

[22] សេចក្តីសម្រេចលើការដាក់បង្ហាញឯកសារ, កថាខណ្ឌ ៣២ ("ក្នុងករណីនេះអង្គជំនុំជម្រះ សូមរំឭកទៅភាគីថា ឯកសារដែលត្រូវបានដាក់បង្ហាញ គឺមិនទាន់ត្រូវបានទទួលយក ដោយគ្រាន់តែតាមរយៈការបញ្ជូនទៅភាគីនៅឡើយទេ។ អង្គជំនុំជម្រះសាលាដំបូងមិនអាចសំអាងលើឯកសារទាំងនោះនៅក្នុងការធ្វើសេចក្តីសម្រេចណាមួយ ឬ សម្រាប់ប្រើប្រាស់ក្នុងសាលក្រមរបស់ខ្លួនឡើយ រហូតទាល់តែឯកសារទាំងនោះ ត្រូវបានទទួលយកជាភស្តុតាង និង ត្រូវបានលើកយកមកពិភាក្សាដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ស្របតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង។ កត្តានេះកាត់បន្ថយបានច្រើននូវព្យសនកម្មដែលមេធាវីការពារក្តី ខៀវ សំផន បានចោទប្រកាន់ថា ពួកខ្លួនបានទទួលរងនូវព្យសនកម្មពីការដាក់បង្ហាញឯកសារទាំងអស់នេះ")។

[23] *រដ្ឋអាជ្ញា ទល់នឹង Karemera និង អ្នកដទៃទៀត*, សាលដីកាលើបណ្តឹងសាទុក្ខបន្ទាន់បន្ទំ របស់ Joseph Nzirorera, អង្គជំនុំជម្រះតុលាការកំពូល (ICTR-98-44-AR73.6), ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៦, កថាខណ្ឌ ១៧។ *រដ្ឋអាជ្ញា ទល់នឹង Sesay និង*

ធ្វើឡើងសំខាន់ដើម្បីជាប្រយោជន៍ដល់មេធាវីការពារក្តីដែលស្ថិតក្នុងស្ថានភាពដ៏ល្អបំផុតក្នុងការសម្រេចថាតើឯកសារមួយណាដែលខ្លួនពិចារណាថាជាឯកសារដោះបន្ទុក[24]។ បន្ទាប់មក មេធាវីការពារក្តីត្រូវសម្រេចថាតើត្រូវស្នើសុំឱ្យទទួលយកសម្ភារៈដែលបានដាក់បង្ហាញនោះដែរ ឬ ទេ។

១១. លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ជាការមិនអាចអនុវត្តបាន និង ជាការពុំចាំបាច់ក្នុងការពិនិត្យមើលការដាក់បង្ហាញទាំងអស់ ដើម្បីសម្រេចថាតើការដាក់បង្ហាញទាំងនោះត្រូវបានកំណត់ត្រឹមត្រូវដែរ ឬ ទេ ថាជាឯកសារដោះបន្ទុកនោះ។ ដូចដែលអង្គជំនុំជម្រះធ្លាប់បានបញ្ជាក់រួចមកហើយ ឯកសារជាច្រើនមានទាំងភស្តុតាងដោះបន្ទុក និង ភស្តុតាងដាក់បន្ទុក ហើយអង្គជំនុំជម្រះនឹងបន្តពឹងផ្អែកទៅលើចេតនាល្អរបស់សហព្រះរាជអាជ្ញាក្នុងការបំពេញការងារ នៅពេលគាត់ដាក់បង្ហាញឯកសារទាំងអស់នេះ[25]។ បើទោះបីជាការដាក់បង្ហាញនេះត្រូវបានសម្រេចថាមានឯកសារខ្លះ ឬ ផ្នែកខ្លះ មិនមានលក្ខណៈដោះបន្ទុកក៏ដោយ គ្រោះថ្នាក់ដែលថាឯកសារទាំងនេះអាចបង្កព្យសនកម្មដល់មេធាវីការពារក្តីគឺមានកម្រិត ដោយសារតែវាជាឆន្ទានុសិទ្ធិរបស់មេធាវីការពារក្តីក្នុងការស្នើសុំ ឬ មិនស្នើសុំឱ្យទទួលយកឯកសារទាំងអស់នេះ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ លើសពីនេះទៀត នៅក្នុងកាលៈទេសៈមួយចំនួន នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងពិចារណាថាតើត្រូវទទួលយកឯកសារបែបនេះទៅតាមសំណើរបស់ខ្លួន អង្គជំនុំជម្រះនឹងធ្វើការសម្រេចបែបនេះ តែក្នុងករណីភាគីទាំងអស់ រួមទាំងមេធាវីការពារក្តី បានទទួលឱកាសក្នុងបញ្ចេញមតិរួចហើយប៉ុណ្ណោះ។ ហេតុដូច្នេះ សំណើរបស់មេធាវីការពារក្តីដែលតម្រូវឱ្យសហព្រះរាជអាជ្ញាកំណត់អត្តសញ្ញាណជាក់លាក់ទៅលើសម្ភារៈដែលអាចដោះបន្ទុក ត្រូវបានបដិសេធ។

## ៣.២ កំណត់ហេតុស្តាប់ចម្លើយកន្លងមក

១២. អង្គជំនុំជម្រះក៏បានបង្គាប់ផងដែរឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយកន្លងមករបស់បុគ្គលដែលមកផ្តល់សក្ខីកម្មទាំងអស់។ ដើម្បីជាប្រយោជន៍យុត្តិធម៌ អង្គជំនុំជម្រះនឹងបន្តការអនុវត្តបែបនេះ

---

*អ្នកដទៃទៀត*, Sesay – សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី សុំដាក់បង្ហាញឯកសារ អនុលោមតាមវិធាន ៦៦ និង ៦៨ នៃវិធានផ្ទៃក្នុង, អង្គជំនុំជម្រះសាលាដំបូង (SCSL-2004-15-T), ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៤, កថាខណ្ឌ ៣៩។ *រដ្ឋអាជ្ញា ទល់នឹង Blaškić, សាលដីកាលើសំណើរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ សុំឱ្យបង្ហាញសម្ភារៈ ផ្អាក ឬ ពន្យារពេលកាលបរិច្ឆេទសារណា និង ការដាក់ឯកសារបន្ថែម,* អង្គជំនុំជម្រះតុលាការកំពូល (IT-95-14) ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០០, កថាខណ្ឌ ៣៨។

[24] *រដ្ឋអាជ្ញា ទល់នឹង Blagojević និង អ្នកដទៃទៀត*, ដីកាសម្រេចរួមលើសំណើ ទាក់ទងការបង្ហាញភស្តុតាង, អង្គជំនុំជម្រះសាលាដំបូង ២ (IT-02-60-PT), ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០២, កថាខណ្ឌ ២១។

[25] សេចក្តីសម្រេចលើការដាក់បង្ហាញឯកសារ, កថាខណ្ឌ ២២, ២៤, ៣៦។

ហើយអង្គជំនុំជម្រះ នឹងពិចារណាលើសំណើសុំឱ្យទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយមុនៗ ទាំងអស់របស់សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្ម។ ក្នុងពេលកន្លងមក ដោយសារតែវិធីសាស្ត្រជាដំណាក់កាលរបស់អង្គជំនុំជម្រះក្នុងការជ្រើសរើសសាក្សីនោះ អង្គជំនុំ-ជម្រះបានបង្គាប់ឱ្យសហព្រះរាជអាជ្ញា ដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីទាំងអស់ ដែលត្រូវបានស្នើឱ្យមកផ្តល់សក្ខីកម្ម[26]។ អង្គជំនុំជម្រះបានផ្តល់ដល់ភាគីនូវបញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញ សម្រាប់ប្រធានបទចុងក្រោយក្នុងសំណុំរឿង ០០២/០២ ហើយបាន សម្រេចទៅលើសំណើសុំស្តាប់សាក្សីបន្ថែមទាំងអស់។ ហេតុដូច្នេះហើយ អង្គជំនុំជម្រះលែងចាត់ ទុកថាជាការចាំបាច់ទៀតហើយ ដែលសហព្រះរាជអាជ្ញាត្រូវដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយ ទាំងអស់របស់សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានស្នើឱ្យមកផ្តល់សក្ខីកម្មនោះ។ មាន តែកំណត់ហេតុស្តាប់ចម្លើយរបស់បុគ្គល ដែលត្រូវបានអង្គជំនុំជម្រះជ្រើសរើសឱ្យមកផ្តល់សក្ខីកម្ម ប៉ុណ្ណោះដែលគួរតែត្រូវបានដាក់បង្ហាញដល់ភាគីនានា។

## ៣.៣ សំណើសុំតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង

១៣. ក្នុងពេលកន្លងមក អង្គជំនុំជម្រះបានបញ្ជាក់ថា៖

> នៅពេលដែលអង្គជំនុំជម្រះខិតជិតដល់ពេលបិទបញ្ចប់ការពិនិត្យភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ ត្រូវតែមានចំណុចណាមួយដែលភាគីអាចសំអាងទៅលើកំណត់ហេតុភ័ស្តុតាង ដែលត្រូវបាន បង្កើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ និង ការជំនុំជម្រះក្នុងសំណុំរឿងនេះ។ តម្លៃនៃ ភ័ស្តុតាងបន្ថែមដែលអាចជួយដល់ការបញ្ជាក់ការពិតត្រូវតែថ្លឹងជាមួយភាពមិនជាក់លាក់ដែលមាន តាមរយៈការអនុញ្ញាតឱ្យទទួលយកនូវភស្តុតាងថ្មីមួយចំនួនធំ នៅពេលជិតបិទបញ្ចប់កិច្ចនីតិវិធី នៅពេលដែលភាគីដទៃទៀត មិនអាចមានឱកាសគ្រប់គ្រាន់ដើម្បីវាយតម្លៃ និង ឆ្លើយតបចំពោះ ព័ត៌មាននេះ។ តាមហេតុផលនេះ អង្គជំនុំជម្រះនឹងពិនិត្យទៅលើសំណើនានា ដែលសុំឱ្យទទួលយក នូវភ័ស្តុតាងថ្មី នៅដំណាក់កាលចុងក្រោយនៃសវនាការនេះ ក្រោមការត្រួតពិនិត្យដ៏តឹងតែង ជា ពិសេសនៅពេលដែលភ័ស្តុតាងនេះ ធ្លាប់មានពីមុនសម្រាប់ភាគី ហើយនៅពេលដែលភ័ស្តុតាងថ្មី ត្រូវបានស្នើសុំសម្រាប់គោលបំណងផ្ទៀងផ្ទាត់ ដោយគ្មានការបញ្ជាក់ច្បាស់លាស់ថា ការទទួល យកភ័ស្តុតាងទាំងនេះ គឺជាការចាំបាច់ដើម្បីប្រយោជន៍យុត្តិធម៌នោះទេ[27]។

---

[26] សេចក្តីសម្រេចលើការដាក់បង្ហាញឯកសារ, កថាខណ្ឌ ២៦ ដល់២៧។

[27] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី អនុលោមតាម វិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង, ឯកសារ E319/47/3, ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦, កថាខណ្ឌ ២៣។

៣.៣.១ *កាលបរិច្ឆេទកំណត់ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦*

១៤. អង្គជំនុំជម្រះមានកាតព្វកិច្ចអនុវត្តកិច្ចដំណើរការនីតិវិធីនៅក្នុងលក្ខណៈមួយដែលធានាបានភាពឆាប់រហ័ស សុវត្ថិភាពផ្នែកគតិយុត្តិ និង តម្លាភាព ដោយបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ក្នុងពេលវេលាសមស្របមួយ[28]។ ក្នុងការបំពេញកាតព្វកិច្ចនេះ អង្គជំនុំជម្រះចាំបាច់ត្រូវធានាផងដែរថា កិច្ចដំណើរការនីតិវិធីមានការដេញដោល ហើយភាគីអាចទទួលបានសមភាពនៃកម្លាំង។ គោលការណ៍ស្ដីពីសមភាពនៃកម្លាំងរួមមានសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និង មានលក្ខខណ្ឌមួយចំនួន ក្នុងនោះមានលក្ខខណ្ឌថា ភាគីនីមួយៗទទួលបានឱកាសសមស្របក្នុងការបង្ហាញរឿងក្ដីរបស់ខ្លួន ក្នុងស្ថានភាពមួយដែលមិនធ្វើឱ្យស្ថិតក្នុងស្ថានភាពលំបាកខ្លាំងធៀបទៅនឹងភាគីម្ខាងទៀត[29]។ សិទ្ធិទទួលបានសវនាការដោយមានការដេញដោល មានន័យថា ទាំងរដ្ឋអាជ្ញា និង មេធាវីការពារក្ដី ចាំបាច់ត្រូវទទួលបានឱកាសដឹងឮ និង បានបញ្ចេញមតិយោបល់លើការលើកឡើងផ្សេងៗដែលបានដាក់ និង ភស្តុតាងដែលបានបង្ហាញរបស់ភាគីដទៃ[30]។

១៥. នៅក្នុងការថ្លឹងថ្លែងលើគោលការណ៍ទាំងអស់នេះ អង្គជំនុំជម្រះសម្រេច ដោយមានករណីលើកលែងដូចកត់សម្គាល់ខាងក្រោមថា អង្គជំនុំជម្រះមិនអាចទុកឱ្យកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ននៅបើកចំហរទទួលយកភស្តុតាងថ្មី ដោយមិនមានពេលកំណត់ឡើយ ដោយសារការធ្វើបែបនេះនឹងមិននាំទៅដល់ការបញ្ចប់សំណុំរឿងនេះដោយយុត្តិធម៌ និង ទាន់ពេលវេលាឡើយ[31]។ អង្គជំនុំជម្រះយល់ឃើញថា ភាគីនានា រួមទាំងសហព្រះរាជអាជ្ញា មានឱកាសគ្រប់គ្រាន់ក្នុងការស្នើសុំដាក់ភស្តុ-តាងក្នុងអំឡុងពេលស៊ើបអង្កេតបីឆ្នាំ ក្នុងអំឡុងសវនាការក្នុងសំណុំរឿង ០០២/០១ ពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០១៤ និង ក្នុងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន ពីខែតុលា ឆ្នាំ ២០១៤ រហូតដល់ពេលបច្ចុប្បន្ននេះ[32]។

---

[28] វិធាន ២១(១) និង ៨៥ នៃវិធានផ្ទៃក្នុង, សេចក្ដីសម្រេច *Prlić*, កថាខណ្ឌ ១៤។

[29] *រដ្ឋអាជ្ញា ទល់នឹង Tadic,* អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការ ICTY (Case No. IT-94-1-A), សាលដីកា, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩, កថាខណ្ឌ ៤៨។

[30] រឿងក្ដី *Edwards* និង *Lewis ទល់នឹង the United Kingdom* (Ap. Nos. 39647/98 និង 40461/98), ECtHR Grand Chamber, សាលក្រម, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤, ទំព័រ ១៦។

[31] *សូមមើលផងដែរ,* សេចក្ដីសម្រេចលើការដាក់បង្ហាញឯកសារ, កថាខណ្ឌ ៤១។

[32] *សូមមើល* សាលក្រមសំណុំរឿង ០០២/០១, ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ២ ដល់៣។

១៦. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា នៅមានសំណើតិចតួចដែលរង់ចាំការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការអនុញ្ញាតឱ្យដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីពីការស៊ើបអង្កេតដែលកំពុងបន្ត ក្នុងសំណុំរឿង ០០៣ និង សំណុំរឿង ០០៤ ហើយថា មិនអាចមិនគិតដល់ចំណុចថា ភ័ស្តុតាងថ្មីៗសំខាន់ៗអាចត្រូវបានរកឃើញក្នុងសំណុំរឿងទាំងអស់នេះដែលអាចនាំដល់ការស្វែងរកការពិតនៅក្នុងសំណុំរឿង ០០២/០២[33] នោះឡើយ។ យ៉ាងណាក៏ដោយ អង្គជំនុំជម្រះចាំបាច់ត្រូវតែថ្លឹងថ្លែងរវាងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំ-ជម្រះក្នុងពេលវេលាសមស្របមួយជាមួយនឹងកាតព្វកិច្ចរបស់អង្គជំនុំជម្រះ ក្នុងការធានានូវសម-ភាពរវាងគូភាគី និង កិច្ចដំណើរការនីតិវិធីដោយមានការដេញដោល។ ដោយសារមូលហេតុនេះហើយ ទើបអង្គជំនុំជម្រះបានដាក់ចេញកាលបរិច្ឆេទកំណត់ ដែលនឹងផ្តល់ដល់មេធាវីការពារក្តីនូវពេលវេលាគ្រប់គ្រាន់ដើម្បីឆ្លើយតបចំពោះភ័ស្តុតាងដែលបានស្នើឡើងរបស់សហព្រះរាជអាជ្ញា មុនពេលបិទកិច្ចដំណើរការនីតិវិធីលើភ័ស្តុតាង។ ការអនុវត្តដោយឱ្យសហព្រះរាជអាជ្ញាអន្តរជាតិដាក់សារណាបែបនេះក្រោយថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ នឹងធ្វើឱ្យពន្យារពេលសំណុំរឿងដោយមិនចាំបាច់ ដោយហេតុថា អង្គជំនុំជម្រះមានសំណុំរឿងយ៉ាងធំនៅចំពោះមុខរួចទៅហើយ ដែលក្នុងនោះមានភ័ស្តុតាងរាប់ពាន់។

១៧. ការដាក់បង្ហាញជាបន្តបន្ទាប់ពីកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ជាលក្ខណៈពិសេសមួយនៃសវនាការនេះ។ ដោយសារមូលដ្ឋាននៃសំណុំរឿងទាំងនេះទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងសំណុំរឿង ០០២/០២ ការស៊ើបអង្កេតក្នុងសំណុំរឿងទាំងនេះ ប្រហែលជានៅតែបន្តបង្កើតភ័ស្តុតាងដែល *តាមការពិនិត្យជាបឋម* មានភាពពាក់ព័ន្ធ។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះមិនអាចរង់ចាំរហូតដល់ពេលបិទកិច្ចស៊ើបសួរទាំងអស់ ដែលមិនទាន់មានការកំណត់កាលបរិច្ឆេទនៅឡើយ ដើម្បីបញ្ចប់សំណុំរឿងនេះទេ[34]។ ទោះជាយ៉ាងនេះក្តី ប្រសិនបើភ័ស្តុតាងថ្មីត្រូវបានរកឃើញពីសំណុំរឿង ០០៣ និង ០០៤ នៅពេលវេលាមួយដែលមិនអាចដាក់ចូលទៅក្នុងកិច្ច-ដំណើរការនីតិវិធីទាំងអស់នេះបាន ពេលនោះ សហព្រះរាជអាជ្ញានឹងមានឱកាសប្តឹងសាទុក្ខស្នើសុំ

[33] ប្រតិចារឹកថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦, ទំព័រ ៣៥ ដល់៣៦។

[34] សេចក្តីសម្រេចលើការដាក់បង្ហាញឯកសារ, កថាខណ្ឌ ("ទាក់ទងសំណើជាជម្រើសមួយទៀត របស់មេធាវីការពារក្តី ស្នើសុំផ្អាកកិច្ចដំណើរការនីតិវិធី រហូតដល់ពេលមានដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៣ និង ០០៤ អង្គជំនុំជម្រះពិចារណាឃើញថា ការផ្អាកកិច្ចដំណើរការនីតិវិធីសវនាការ ដូចដែលបានស្នើឡើងនេះ គឺផ្ទុយទៅនឹងគោលការណ៍នៃការបញ្ចប់សំណុំរឿងនេះដោយប្រសិទ្ធិភាព និង ដោយយុត្តិធម៌ ហើយនឹងរំលោភសិទ្ធិជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័ស។ ហេតុដូច្នេះ អង្គជំនុំជម្រះពិចារណាឃើញថា ការធ្វើដូច្នេះពុំមែនដើម្បីប្រយោជន៍យុត្តិធម៌ឡើយ")។

ឲ្យធ្វើការពិចារណាទៅលើភ័ស្តុតាងបែបនេះ ប្រសិនបើសហព្រះរាជអាជ្ញាយល់ឃើញថា ភ័ស្តុតាងនេះអាចជាកត្តាសម្រេចនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះ[35]។

១៨. តាមសំអាងហេតុទាំងអស់នេះ អង្គជំនុំជម្រះយល់ឃើញថា អង្គជំនុំជម្រះចាំបាច់ត្រូវរក្សា កាលបរិច្ឆេទកំណត់ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ សម្រាប់សំណើសុំ តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង របស់សហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

១៩. ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះកត់សម្គាល់ថា ដោយសារតែភ័ស្តុតាងដែលអាចដោះបន្ទុក ចាំបាច់ត្រូវតែដាក់បង្ហាញរហូតដល់បញ្ចប់សវនាការ មេធាវីការពារក្តីអាចធ្វើសំណើសុំ តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅក្រោយកាលបរិច្ឆេទកំណត់ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ នេះ។ ដើម្បីរក្សាសមភាពរវាងគូភាគី តាមកាលៈទេសៈពិសេសនៃសំណុំរឿងនេះ និង នៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ ហើយក៏ដើម្បីអនុញ្ញាតឲ្យមានការសួរដេញដោលពេញលេញទៅលើភ័ស្តុតាង អង្គជំនុំជម្រះសម្រេចថា សហព្រះរាជអាជ្ញាចាំបាច់ត្រូវទទួលបានឱកាសក្នុងការជំទាស់ចំពោះភ័ស្តុតាងដែលបានបង្ហាញដោយមេធាវីការពារក្តី ជាពិសេសក្នុងករណីដែលភ័ស្តុតាងនោះផ្លាស់ប្តូរជាសារវន្តនូវលក្ខណៈនៃរឿងក្តីរបស់មេធាវីការពារក្តី[36]។ ហេតុដូច្នេះ ជាករណីលើកលែងចំពោះកាលបរិច្ឆេទកំណត់ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ នេះ អង្គជំនុំជម្រះនឹងពិចារណាលើសំណើរបស់សហព្រះរាជអាជ្ញា ឬ របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលសុំឲ្យទទួលយកភ័ស្តុតាងថ្មីដើម្បីបដិសេធទៅលើភ័ស្តុតាងថ្មីៗដែលជនជាប់ចោទបានស្នើសុំ ហើយដែលត្រូវបានទទួលយកដោយអង្គជំនុំជម្រះ នៅក្រោយកាលបរិច្ឆេទកំណត់នេះ។

២០. សក្ខីកម្មរបស់អ្នកជំនាញក៏ជាករណីលើកលែងចំពោះកាលបរិច្ឆេទកំណត់ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ នេះដែរ។ អ្នកជំនាញមួយចំនួននៅមិនទាន់មកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ នៅឡើយ ហើយភាគីនានា នៅពេលត្រៀមរៀបចំការសួរដេញដោល អាចរកឃើញភ័ស្តុតាងថ្មីដែលអាចជួយដល់ការសួរដេញដោលបុគ្គលទាំងអស់នេះ។ អង្គជំនុំជម្រះបានដាក់ចេញកាលបរិច្ឆេទកំណត់ផ្សេងសម្រាប់សំណើតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ទាក់ទងនឹងសក្ខីកម្មរបស់អ្នកជំនាញ ហើយអង្គជំនុំជម្រះនឹងបន្តធ្វើបែបនេះ ដោយក្នុងករណីខ្លះដាក់ពេលវេលាកំណត់នៅ

---

[35] វិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង។

[36] *រដ្ឋអាជ្ញា ទល់នឹង Aleksovski*, អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការ ICTY, សាលដីកាលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញា ស្តីពីភាពអាចទទួលយកបាននៃភ័ស្តុតាង, ថ្ងៃ ទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៩, កថាខណ្ឌ ២៦។

ក្រោយថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦។ សំណើទាំងអស់នេះនឹងត្រូវបដិសេធចោល ប្រសិនបើភស្តុតាងដែលស្នើសុំ មិនពាក់ព័ន្ធនឹងការសួរដេញដោលអ្នកជំនាញទេនោះ។

២១. ដោយពិចារណាទៅលើចំណុចទាំងអស់ខាងលើ អង្គជំនុំជម្រះយល់ឃើញថា កាលបរិច្ឆេទកំណត់ខាងលើបានថ្លឹងថ្លែងយ៉ាងសមស្របអំពីសិទ្ធិរបស់ភាគីធៀបជាមួយនឹងតម្រូវការក្នុងការបញ្ចប់សំណុំរឿងនេះ ក្នុងពេលវេលាមួយសមស្រប។

២២. ចំពោះកាលបរិច្ឆេទកំណត់ក្នុងការឆ្លើយតប អង្គជំនុំជម្រះអនុញ្ញាតតាមសំណើរបស់មេធាវីការពារក្ដី សុំធ្វើការឆ្លើយតបនៅមុន ឬ នៅត្រឹម**<u>ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៦</u>** ចំពោះសំណើនានា តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលបានដាក់នៅមុន ឬ ត្រឹមថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ និងដាក់សំណើតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ណាមួយដោយក្រុមមេធាវីការពារក្ដីខ្លួនឯង ដែលចាំបាច់ធ្វើឡើងដោយសារតែភស្តុតាងថ្មី ដែលសហព្រះរាជអាជ្ញាបានដាក់។ ភាគីនានាត្រូវបានផ្ដល់ឱ្យនូវបញ្ជីឈ្មោះសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និង អ្នកជំនាញ សម្រាប់ប្រធានបទសវនាការចុងក្រោយ ដូចដែលមេធាវីការពារក្ដី ខៀវ សំផន បានស្នើសុំក្នុងឯកសារ E421/2 កាលពីថ្ងៃទី ១៤ ខែ កញ្ញា។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា មេធាវីការពារក្ដី ខៀវ សំផន នឹងមានពេលវេលាគ្រប់គ្រាន់ក្នុងការឆ្លើយតបចំពោះបញ្ជីនេះ ដោយដាក់សំណើសុំឱ្យទទួលយកភស្តុតាងថ្មី ត្រឹមថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៦[37]។

២៣. ដូចដែលបានបញ្ជាក់រួចមកហើយ អង្គជំនុំជម្រះបានឈានចូលដល់ដំណាក់កាលចុងក្រោយនៃសំណុំរឿង ០០២/០២ ហើយរំពឹងថា នឹងបញ្ចប់កិច្ចដំណើរការនីតិវិធីលើភស្តុតាងក្នុងសំណុំរឿង ០០២/០២ ត្រឹមខែធ្នូ ឆ្នាំ ២០១៦[38]។ ដោយសារតែដំណាក់កាលបញ្ចប់សវនាការឈានចូលជិតមកដល់ហើយនោះ ជាចាំបាច់ណាស់ដែលភាគីទាំងអស់ត្រូវគោរពដល់ភាពចាំបាច់ក្នុងការឆ្លើយតបឱ្យបានឆាប់រហ័សចំពោះការវិវត្តថ្មីៗក្នុងសំណុំរឿង។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា មេធាវីការពារក្ដីត្រូវតែឆ្លើយតបចំពោះការដាក់បង្ហាញភស្តុតាងដែលអាចដោះបន្ទុក ដែលធ្វើឡើង

[37] *សូមមើល* សំណើសុំបញ្ជីសាក្សីស្ថាពរ។ អង្គជំនុំជម្រះសូមរំឭកថា ពេលវេលាកំណត់ផ្សេងគឺថ្ងៃទី ៣១ ខែ សីហា ត្រូវបានដាក់ដើម្បីឆ្លើយតបចំពោះ សំណើរបស់សហព្រះរាជអាជ្ញា ឯកសារ E319/52 ផ្អែកលើកាលៈទេសៈពាក់ព័ន្ធ។

[38] អនុស្សរណៈស្ដីពីពេលវេលាកំណត់, កថាខណ្ឌ ១។

ក្រោយថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ តាមរយៈសំណើសុំ តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក្នុងរយៈពេលពីរសប្តាហ៍បន្ទាប់ពីទទួលបានការដាក់បង្ហាញ[39]។

២៤. ជាចុងក្រោយ អង្គជំនុំជម្រះសូមរម្លឹកថា ដោយសារតែលក្ខខណ្ឌតម្រូវបច្ចេកទេសសម្រាប់ការផ្ទេរឯកសារដាក់បង្ហាញថ្មី ពីសំណុំរឿង ០០៣ និង ០០៤ មកក្នុងសំណុំរឿង ០០២/០២ រួមទាំងការដាក់លេខឯកសារថ្មីឡើងវិញ ទើបមានគម្លាតពេលវេលា ពីពេលដាក់សំណើសុំដាក់បង្ហាញឯកសាររហូតដល់ពេលដែលឯកសារទាំងនោះត្រូវបានផ្តល់ជូនទៅដល់ភាគីនានា។ នៅក្នុងកាលៈទេសៈនេះ ពេលវេលាឆ្លើយតបនឹងចាប់គិតពីពេលដែលភាគីបានទទួលឯកសារដែលដាក់បង្ហាញ ឬ ពេលដែលសហព្រះរាជអាជ្ញាស្នើសុំ។ ហេតុដូច្នេះ សំណើសុំរបស់មេធាវីការពារក្តី ខៀវ សំផន ត្រង់ចំណុចនេះត្រូវបានអនុញ្ញាត[40]។

**តាមសំអាងហេតុដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូង៖**

**អនុញ្ញាត** ចំពោះសំណើរបស់ នួន ជា សុំឱ្យរក្សាទុកកាលបរិច្ឆេទកំណត់ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ សម្រាប់សំណើសុំ តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងដែលដាក់ដោយសហព្រះរាជអាជ្ញា។

**កត់សម្គាល់** ថា អង្គជំនុំជម្រះនឹងពិចារណាទៅលើសំណើរបស់សហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យទទួលយកភស្តុតាងថ្មី ក្នុងករណីដែលពួកគេស្នើសុំជំទាស់ចំពោះភស្តុតាងថ្មីដែលមេធាវីការពារក្តីបានស្នើសុំ ហើយត្រូវបានអង្គជំនុំជម្រះទទួលយកនៅក្រោយថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦។

**អនុញ្ញាតតាម** សំណើសុំរបស់មេធាវីការពារក្តី នួន ជា និង ខៀវ សំផន សុំពន្យាកាលបរិច្ឆេទរហូតដល់ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៦ ដើម្បីឆ្លើយតបចំពោះសំណើសុំ តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង បន្ទាប់ពីមានឯកសារ E319/52 និង នៅមុនថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ ឬ ត្រូវដាក់សំណើសុំ តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដោយខ្លួនឯង ដោយសារតែការដាក់បង្ហាញដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា នៅក្នុងអំឡុងពេលវេលានោះ។

[39] ភាគីត្រូវបានជូនដំណឹងអំពីការអាចស្វែងរកបាន នូវកំណត់ហេតុស្តាប់ចម្លើយ ឬ ឯកសារដែលបានដាក់បង្ហាញដទៃទៀត តាមរយៈការជូនដំណឹងពីសំណុំរឿង ដែលរៀបរាប់ពីបញ្ជីឯកសារទាំងអស់ ហើយបានផ្តល់នូវតំណភ្ជាប់ Zylab ចំពោះឯកសារទាំងអស់នេះ (*សូមមើល* ជាឧទាហរណ៍, ការជូនដំណឹងពីសំណុំរឿង ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ ស្តីពីឯកសារដែលត្រូវបានដាក់បង្ហាញ នៅក្នុងឯកសារ E319/50)។ មេធាវីការពារក្តីនឹងមានពេលវេលា ១៤ថ្ងៃ ក្រោយពេលជូនដំណឹងពីសំណុំរឿងនេះ ដើម្បីដាក់សំណើសុំតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលពាក់ព័ន្ធនានា។

[40] សំណើសុំពន្យាពេល, កថាខណ្ឌ ១០ ដល់១២។

01329143



**ជូនដំណឹង** ដល់ភាគីថា អង្គជំនុំជម្រះនឹងចាត់ទុកថាយឺតពេល ចំពោះសំណើសុំ តាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង ទាំងឡាយណាដែលមេធាវីការពារក្ដីបានដាក់ ទាក់ទងនឹងឯកសារសំណុំរឿង 00៣ និង 00៤ ប្រសិនបើដាក់ហួសរយៈពេល ១៤ ថ្ងៃ បន្ទាប់ពីមានការជូនដំណឹងពីការដាក់បង្ហាញឯកសារ។

**ជូនដំណឹង** ដល់ភាគីថា សារណា តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ទាក់ទងនឹងអ្នកជំនាញដែលត្រូវកោះហៅដោយអង្គជំនុំជម្រះ នឹងត្រូវកំណត់កាលបរិច្ឆេទផ្សេង។

**បដិសេធ** សំណើរបស់មេធាវីការពារក្ដី នួន ជា សុំឱ្យបង្គាប់ឱ្យសហព្រះរាជអាជ្ញាកំណត់អត្តសញ្ញាណចំណុចដែលអាចដោះបន្ទុក នៅក្នុងឯកសារដែលបានដាក់បង្ហាញ និង

**បញ្ជាក់ថា** សហព្រះរាជអាជ្ញាមានកាតព្វកិច្ចកំណត់អត្តសញ្ញាណសម្ភារៈដែលអាចដោះបន្ទុក ដែលសហព្រះរាជអាជ្ញាមាន ដោយកាតព្វកិច្ចនេះនឹងបន្តរហូតដល់ចុងបញ្ចប់នៃសំណុំរឿង 00២/0២។

ភ្នំពេញ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២0១៦

**ជ. ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE PREMIERE INSTANCE

**យ៉ា សុខន**